## សុន្ទរកថារបស់**លោក គូរ៉ូមីយ៉ា តាកាយ៉ូស៊ី**
## ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីគំរប់ខួប៥ឆ្នាំ នៃកិច្ចសហប្រតិបត្តិការរបស់ជេម៉ាស់ និង ស៊ីម៉ាក់ ក្នុង សកម្មភាពគាំទ្រការអភិវឌ្ឍសហគមន៍ និង ការបោសសំអាតមីន
## (គម្រោងជំនួយរបស់រដ្ឋាភិបាលជប៉ុន និង ក្រុមហ៊ុនកុម៉ាត់ស៊ុ)
## ថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០១៣
## ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង

សូមគោរពឯកឧត្តម ប្រាជ្ញ ច័ន្ទ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង។
សូមគោរពឯកឧត្តម ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC)
សូមគោរពលោក NOJI KUNIO ជានាយកប្រតិបត្តិ និង ជាតំណាងក្រុមហ៊ុន KOMATSU
សូមគោរពលោក NONAKA MITSUO ប្រធានអង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)
សូមគោរពលោក សើ សាម៉េត អភិបាលនៃគណៈអភិបាលស្រុក រតនៈមណ្ឌល
និង ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទាំងអស់ដែលមានវត្តមាននៅទីនេះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែង ដែលបានទទួលការអញ្ជើញឲ្យចូលរួម ក្នុងពិធីគំរប់ខួប៥ឆ្នាំ នៃកិច្ចសហប្រតិបត្តិការរបស់ស៊ីម៉ាក់ និងជេម៉ាស់ក្នុងសកម្មភាពគាំទ្រការអភិវឌ្ឍសហគមន៍ និង ការបោសសំអាតមីនថ្ងៃនេះ ក្រោមអធិបតេយ្យភាព ឯកឧត្តម ប្រាជ្ញ ច័ន្ទ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់គ្នាដែលបានចូលរួមក្នុងការរៀបចំកម្មវិធីសម្រាប់ថ្ងៃនេះ។

លើសពីនេះទៀត ខ្ញុំមានអារម្មណ៍សប្បាយរីករាយជាពិសេសដោយឆ្នាំ២០១៣នេះជាឆ្នាំគំរប់ខួបទី៦០ នៃចំណងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រជប៉ុនដែលបានចាប់ផ្តើមតាំងពី

ឆ្នាំ១៩៥៣មក។ ខ្ញុំគិតថា ឱកាសនេះនឹងអាចជួយជំរុញបន្ថែមទៀតនូវទំនាក់ទំនង រវាងប្រទេសកម្ពុជា និង ប្រទេសជប៉ុនឲ្យកាន់តែប្រសើរឡើង។

ដូចដែលអ្នកទាំងអស់គ្នាបានដឹងហើយថា ដោយសារសង្គ្រាមផ្ទៃក្នុងអស់រយៈពេលជាច្រើនឆ្នាំ ប្រទេសកម្ពុជាត្រូវបានគេនិយាយថាមានគ្រាប់មីនលើសពី៤លានគ្រាប់បន្សល់ទុកនៅក្នុងដីនៅប៉ែកពាយ័ព្ទនៃប្រទេសនេះនៅឡើយ។ ចំពោះប្រទេសកម្ពុជា វត្តមាននៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនិង គ្រាប់មីនគឺជាឧបសគ្គដ៏ធំមួយ និងជាបញ្ហារាំងស្ទះការអភិវឌ្ឍវិស័យកសិកម្ម អភិវឌ្ឍជនបទ ហេដ្ឋារចនាសម្ព័ន សង្គម និង សេដ្ឋកិច្ច។ ដូចនេះ ការបោសសំអាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះគឺជាដំណើរការចាំបាច់ដើម្បីការអភិវឌ្ឍប្រទេសនេះ។

ស្ថិតក្នុងកាលទេសៈបែបនេះខ្ញុំបានដឹងថា ចាប់តាំងពីឆ្នាំ ២០០២មក អង្គការជេម៉ាស់ ប្រចាំប្រទេសកម្ពុជា ដោយសហការជាមួយស៊ីម៉ាក់ បាននិងកំពុងប្រើប្រាស់កិច្ចសហប្រតិបត្តិការជំនួយឥតសំណងសំរាប់អង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសជប៉ុន សម្រាប់គម្រោងបោសសំអាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដោយចាប់ផ្តើមនៅខេត្តព្រៃវែង  និងរហូតដល់ពេលបច្ចុប្បន្ននេះ បានអភិវឌ្ឍន៍សកម្មភាពទៅលើគោលដៅខេត្តចំនួន១៣។ អស់រយៈពេល១០ឆ្នាំហើយដែលជេម៉ាស់បានធ្វើការបោសសំអាតមីន និង ផ្ទេរបច្ចេកទេសក្នុងការបោសសម្អាតមីនជាច្រើនដល់ស៊ីម៉ាក់ដែលពិតជាបានរួមចំណែកដល់ការកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជា ។

លើសពីនេះទៅទៀត ខ្ញុំបានឮថាចាប់តាំពីឆ្នាំ២០០៨មក ក្រុមហ៊ុនកុម៉ាត់ស៊ុបានប្រគល់ គ្រឿងចក្របោសសំអាតមីនប្រឆាំងមនុស្សជាដើមជូនជេម៉ាស់ដោយឥតសំណង និងសហការជាមួយជេម៉ាស់ក្នុងគម្រោងជំនួយសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលមិនត្រឹមតែធ្វើសកម្មភាពបោសសំអាតមីនប៉ុណ្ណោះទេ តែថែមទាំងរួមចំណែកអភិវឌ្ឍន៍សហគមន៍ទៀតផងដែលនេះជាទង្វើដ៏គួរឲ្យគោរព និងកោតសរសើរបំផុត។

ក្នុងនាមស្ថានទូតជប៉ុន ខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែងដែលវិស័យសាធារណៈ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដែលសុទ្ធសឹងជាភាគីជប៉ុន ធ្វើការរួបរួមគ្នាដើម្បីដោះស្រាយបញ្ហាមីន ដែលជាប្រធានបទសំខាន់នៅប្រទេសកម្ពុជា និង អភិវឌ្ឍន៍សហគមន៍។

សម្រាប់គោលដៅលើកនេះ នៅក្នុងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ការអភិវឌ្ឍសហគមន៍ដែលរួមមានការសាងសង់លូបេតុងចំនួន៣០កន្លែង សាលារៀនចំនួន៤ និងផ្លូវកសិកម្មប្រវែង ២០ គីឡូម៉ែត្រ ត្រូវបានផ្សាភ្ជាប់នឹងការរំដោះផ្ទៃដីចំនួន៤៥៨ហិចតាតាមរយៈការបោសសំអាតមីន។ ការធ្វើសកម្មភាពគាំទ្រជាលក្ខណៈសមាហរណកម្ម ពីការបោសសំអាតមីនរហូតដល់ការកែច្នៃដីបោសសំអាតមីនរួចមកប្រើប្រាស់ អាចនាំមកនូវប្រសិទ្ធភាព និង អត្ថប្រយោជន៍យ៉ាងក្រៃលែងក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រជាជនក្នុងសហគមន៍ ។

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំប្រឹងប្រែងជំរុញបន្ថែមទៀតសម្រាប់សកម្មភាពបោសសំអាតមីនដើម្បីសម្រេចតាមគោលការណ៍ពន្យានៃកតិកសញ្ញា អូតាវ៉ា ក្នុងការបោសសម្អាតមីនប្រឆាំមនុស្សជាតិឲ្យអស់ទាំងស្រុងត្រឹមឆ្នាំ២០១៩។ ចាប់តាំងពីឆ្នាំ ១៩៩២មក រដ្ឋាភិបាលជប៉ុនបានធ្វើការគាំទ្រការបោសសំអាតមីនដោយបានផ្តល់ជំនួយជាង ១២០ កោដយ៉េន ហើយយើងនឹងបន្តផ្តល់ជំនួយជាច្រើនទៀតតាមរយៈស៊ីម៉ាក់ដើម្បីបោសសម្អាតមីនដែលនៅសេសសល់ក្នុងន័យសំដៅគាំទ្រប្រទេសកម្ពុជាដើម្បីសម្រេចតាមគោលដៅ។

ជាចុងក្រោយខ្ញុំនេះ សូមសម្តែងនូវការគោរពនិង ថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅ ចំពោះ អ្នកទាំងអស់គ្នាដែលធ្វើសកម្មភាពបោសសំអាតមីននៅកម្ពុជាដែលជាមជ្ឍដ្ឋានការងារដ៏គ្រោះថ្នាក់។ ព្រមជាមួយគ្នានេះផងដែរ ខ្ញុំសូមជូនពរឲ្យសកម្មភាពបោសសំអាតមីនរបស់ដេម៉ាស់ និង កុម៉ាត់ស៊ុកាន់តែផ្តល់អត្ថប្រយោជន៍ខ្ពស់ដល់ប្រជាជននៅក្នុងសហគមន៍គោលដៅ និង សូមឲ្យកិច្ចសហប្រតិបត្តិការនេះជួយជំរុញចំណងមិត្តភាពរវាងប្រទេសកម្ពុជា និងជប៉ុនឲ្យកាន់តែប្រសើរថែមទៀត។

អគុណចំពោះការចំណាយពេលវេលាតាមដានស្តាប់ ។